**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០២១

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-May-21, 14:28
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ចម្លើយរបស់ មាស មុត តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង**

---

**ដាក់ដោយ ÷**

**សហមេធាវី ៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន ÷**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តី ០០៣**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តាមរយៈនេះ ឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ.") សុំឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង[1]។ សំណើរបស់ ស.ព.អ. មិនអាចទទួលយកបាន និង គួរត្រូវបដិសេធចោល។

## I. សេចក្តីផ្តើម

១. ១៦ ខែ បន្ទាប់ពីពិភាក្សាសម្រេច[2] អង្គបុរេជំនុំជម្រះបានប្រកាសជាឯកច្ឆន្ទថា សហចៅក្រមស៊ើបអង្កេត បានរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ដោយបានសម្រេចដោយចេតនា គេចវេសពីយន្តការដោះស្រាយជម្លោះ និង ចេញដោយខុសច្បាប់ នូវដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា "ទាំងដែលដឹងយ៉ាងច្បាស់អំពីបញ្ហា ដែលនឹងកើតចេញពីសកម្មភាពរបស់ខ្លួន ចំពោះកិច្ចដំណើរការនីតិវិធីនៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក."[3]។ ជាការគួរឱ្យកត់សម្គាល់ ដោយមិនគោរពការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងរឿងក្តី ០០៤/២ អង្គបុរេជំនុំជម្រះមិនបានផ្តល់នូវសំអាងហេតុសមស្របចំពោះការងាកចេញ ឬក៏ពុំផ្តល់នូវការពន្យល់ចំពោះការបដិសេធមិនប្រើប្រាស់ នូវឧបាស្រ័យដែលអង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ឡើង ដែលជាការចៃដន្យគឺជាការលើកឡើងវិញនូវឧបាស្រ័យដែលអង្គបុរេជំនុំជម្រះបានកំណត់រួចហើយ[4]។ ដោយមិនបោះបង់ចោលនូវឱកាសចំពោះការវាយតម្លៃបង្ខូច និង បន្ថោកតម្លៃដោយឥតប្រយោជន៍ ទៅលើសហ

---

[1] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ឯកសារ D270 ("សំណើរបស់ ស.ព.អ.")។

[2] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 & D267/35 ("សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣") កថាខណ្ឌ ៩០ ទំព័រ ៤៦។ ទទ្ធីករណ៍ផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ ត្រូវបានធ្វើឡើង *ជាអសាធារណៈ* នៅ ថ្ងៃទី ២៧-២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

[3] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ៩០, ១០៨។

[4] *រឿងក្តី* អោ អាន សំណុំរឿងលេខ ០០៤/០២/០៧-០៩-២០០៩-អវតក/អជសជ/អជតក សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២") កថាខណ្ឌ ៦១ ដែលដកស្រង់ *រឿងក្តី* អោ អាន សំណុំរឿងលេខ ០០៤/០២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 ("សេចក្តីពិចារណារបស់ អ.ជ.ប. ក្នុងរឿងក្តី ០០៤/២") កថាខណ្ឌ ៣០។

ចៅក្រមស៊ើបអង្កេត និង ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលនោះ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានប្រព្រឹត្តតាមអំពើចិត្តដោយមិនគោរព និង ដោយមិនចាំបាច់ ប្រើប្រាស់នូវភាសា និង របៀបសរសេរ បែបមិនដឹងខុសត្រូវ មានលក្ខណៈហួសហេតុ និង មិនសមរម្យ[5] ដែលហាក់ដូចជាមានចេតនា ដោយល្បិចកលដើម្បីបង្វែរចំណាប់អារម្មណ៍ពី និង បិទបាំងពីការខកខានយ៉ាងហួសហេតុរបស់អង្គបុរេជំនុំជម្រះ មិនបានបំពេញ "ភារកិច្ចតាមផ្លូវតុលាការ ក្នុងការប្រកាស ដោយផ្អែកទៅលើច្បាប់ សេចក្តីសម្រេចលើបញ្ហាដែលមានវិវាទ"[6]។ ដោយមិនប្រយ័ត្ននោះ ការជាប់គាំងដែលបង្កើតឡើងដោយអង្គបុរេជំនុំជម្រះ បើទោះបីជាបានប្រឹក្សាគ្នាយ៉ាងទូលាយរយៈពេល ១៦ ខែ ដើម្បីពិភាក្សា សម្រេច និង ចម្លងចេញពីសេចក្តីពិចារណារបស់ខ្លួន ក្នុង រឿងក្តី ០០៤/២ បែរជាឱ្យប្រផ្នូលអំពីការមិនអាចសម្រេចបាន និង ការបដិសេធមិនយល់ស្រប ដែលអាចមើលឃើញ នៅពេលដែលការស្តីបន្ទោសបានថមថយទៅវិញ ដែលចាំបាច់ត្រូវតែធ្វើនោះ នឹងនាំឱ្យមានការដាក់សំណុំរឿងចូលទៅក្នុងបណ្ណសារ ដូចដែលបានធ្វើឡើងនៅក្នុងរឿងក្តី ០០៤/២។

២. ការ"ចោលទោសជាថ្មីម្តងទៀតទៅលើស្ថានការណ៍ដ៏អាក្រក់ផ្នែកផ្លូវច្បាប់ ដែលសកម្មភាពខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេត បានបង្កើតឡើងចំពោះកិច្ចដំណើរការនីតិវិធីផ្សេងទៀតរបស់ អ.វ.ត.ក."[7] អង្គបុរេជំនុំជម្រះបានប្រកាសយ៉ាងជូរចត់ (ដូចក្នុងរឿងក្តី ០០៤/២) ថា សហចៅក្រមស៊ើបអង្កេត បង្វែរដោយចេតនា និង ដោយគិតគូរច្បាស់លាស់ នូវដំណើរការយុត្តិធម៌ ដោយសារតែ "ពួកគាត់ប្រហែលជាមានចេតនា ធ្វើឱ្យបរាជ័យដល់គោលជំហរដើម ហើយរំខានដល់សិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ"[8] តាមរយៈការព្រមព្រៀងគ្នាចេញ ក្នុងពេលជាមួយគ្នា នូវដីកាដំណោះស្រាយ ដែលផ្ទុយគ្នានិងដាច់ពីគ្នា។ ប៉ុន្តែ ក្រៅពីការជះសម្តីដោយក្តីមួម៉ៅ អង្គបុរេជំនុំជម្រះមិនបានផ្តល់នូវមូលដ្ឋានផ្នែកផ្លូវច្បាប់ណាមួយ សម្រាប់ការអះអាងអំពីចេតនាអាក្រក់របស់សហចៅក្រមស៊ើបអង្កេត ដែលផ្អែកទៅលើការវិភាគរបស់ពួកគេ ទៅលើក្របខណ្ឌរបស់ អ.វ.ត.ក. និងឆន្ទានុសិទ្ធិតាមផ្លូវតុលាការ ដោយឯករាជ្យរបស់ពួកគេ ដែលបានជ្រើសរើសយកការចុះបញ្ជីជាលក្ខណៈផ្ទៃក្នុង នូវការខ្វែងយោបល់គ្នា ដូចមានចែងនៅក្នុងវិធាន ៧២(១) នៃវិធានផ្ទៃក្នុង ហើយ

---

[5] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៣៩-១៤១, ១៤៣-១៤៤, ១៤៦-១៤៨, ១៥៤, ១៦០-១៦១, ២៦០, ២៧៣-២៧៥, ២៧៧-២៨០, ២៨២ - ២៨៣ កំណត់សម្គាល់ ៥៩៥។

[6] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ១២២។

[7] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៩។

[8] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៨។

ចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា និង ដាច់ដោយឡែកពីគ្នា ដែលផ្ទុយពីការប្តឹងទៅអង្គបុរេជំនុំជម្រះ នូវការខ្វែងយោបល់គ្នានោះ[9]។

៣. ដោយមិនត្រូវនឹងច្បាប់ អង្គបុរេជំនុំជម្រះបានចោទប្រកាន់សហចៅក្រមស៊ើបអង្កេតថា ប្រព្រឹត្តដោយចេតនានូវបណ្តាសកម្មភាព ដែលមិនត្រឹមត្រូវ និង មានបំណងអាក្រក់ នៅក្នុងដំណើរការស៊ើបអង្កេត ដែលឈានដល់កម្រិតខ្ពស់បំផុត តាមរយៈការចេញដោយខុសច្បាប់ នូវដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា[10] ដែលដូច្នេះហើយធ្វើឱ្យប៉ះពាល់ដល់ចេតនារបស់ពួកគេ ក្នុងការធ្វើឱ្យខូចខាតដល់លទ្ធផលចុងក្រោយនៃយុត្តិធម៌[11]។ ដោយបកស្រាយវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ថាចែងយ៉ាងច្បាស់អំពីដីកាដំណោះស្រាយតែមួយ ថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងចោទប្រកាន់នោះ[12] អង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេត "បានប្រព្រឹត្តកំហុសលើអង្គច្បាប់ដ៏ធំធេង ដោយសន្និដ្ឋានថា ក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក. អនុញ្ញាតឱ្យចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និង ផ្ទុយគ្នា"[13] "ធ្វើឱ្យប៉ះពាល់ទៅដល់មូលដ្ឋាននៃប្រព័ន្ធចម្រុះ និង ដំណើរការដោយត្រឹមត្រូវរបស់ អ.វ.ត.ក."[14]។ ការទទួលស្គាល់ថា សហចៅក្រមស៊ើបអង្កេត បកស្រាយដោយខុសឆ្គងនូវវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ដោយប្រើប្រាស់

---

[9] ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 កថាខណ្ឌ ៧។ ដីកាដំណោះស្រាយ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 កថាខណ្ឌ ១៩។ ជាការគួរឱ្យកត់សម្គាល់ អង្គបុរេជំនុំជម្រះ ត្រូវបានស្នើឱ្យផ្តល់ការយល់ឃើញរបស់ខ្លួនអំពីច្បាប់៖ ១) ក្នុងករណីមានការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ថាតើត្រូវលើកលែងការចោទប្រកាន់ប្រឆាំងនឹងម្ចាស់បណ្តឹងឧទ្ធរណ៍ ឬត្រូវចោទប្រកាន់គាត់ទៅជំនុំជម្រះ និង ២) ក្នុងករណីដែលការខ្វែងយោបល់គ្នា នៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយអង្គបុរេជំនុំជម្រះ មិនអាចមានសំឡេងភាគច្រើនលើសលប់បាន នៅពេលសម្រេចការខ្វែងយោបល់គ្នានេះ។ អង្គបុរេជំនុំជម្រះបានសម្រេចថា "អង្គបុរេជំនុំជម្រះពុំមានយុត្តាធិការ ដើម្បីដោះស្រាយបញ្ហាជាសម្មតិកម្ម ឬផ្តល់នូវមតិយោបល់ណែនាំនោះទេ"។ *រឿងក្តី យឹម ទិត្យ* សំណុំរឿងលេខ ០០៤/០២/០៧-០៩-២០០៩-អវតក/កសចស (អបជ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៤, ៨។

[10] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០២ -១០៩។

[11] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៨។

[12] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៣។

[13] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ៨៨។ *សូមមើលផងដែរ* កថាខណ្ឌ ១០៥ ដែលអង្គបុរេជំនុំជម្រះបានអះអាងថា សហចៅក្រមស៊ើបអង្កេត បានប្រព្រឹត្ត "កំហុសអង្គច្បាប់ធ្ងន់ធ្ងរ ដែលជាមូលដ្ឋាននៃសំអាងហេតុរបស់ពួកគេ"។

[14] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៦។

ចេតនាអាក្រក់ ក្នុងការអនុវត្តមុខងារតាមផ្លូវតុលាការរបស់ខ្លួន និង ក្នុងការកំណត់ប្រព័ន្ធចម្រុះរបស់ អ.វ.ត.ក. គឺមិនសមហេតុផលឡើយ។

៤. ដោយមិនមានការគាំទ្រ អង្គបុរេជំនុំជម្រះ អះអាងដោយមិនប្រុងប្រយ័ត្នថា សហចៅក្រមស៊ើបអង្កេត "បានដឹងពីការលំបាក ដែលបណ្តាលមកពីសកម្មភាពរបស់ពួកគាត់ មិនត្រឹមតែទៅលើបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះទេ តែហួសពីដំណាក់កាលបណ្តឹងឧទ្ធរណ៍ មុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ទៅទៀត"[15] ប៉ុន្តែដោយឥតខ្វល់ខ្វាយ បែរជាមិនអនុវត្តភារកិច្ចតាមផ្លូវតុលាការរបស់ខ្លួន ក្នុងការសម្រេចលើបញ្ហា ដែលបានប្តឹងមកខ្លួនទៅវិញ[16]។ ជាសម្តីឥតន័យ។ សហចៅក្រមស៊ើបអង្កេត ក្នុងនាមជាចៅក្រមឯករាជ មានសិទ្ធិអនុវត្តច្បាប់ តាមការយល់ឃើញរបស់ខ្លួន និង មានសិទ្ធិជ្រើសរើសកិច្ចរបស់ខ្លួន។ ទោះបីជាអង្គបុរេជំនុំជម្រះ អាចមិនយល់ស្របជាមួយសំអាងហេតុផ្នែកផ្លូវច្បាប់ សម្រាប់ការចេញដីកាដំណោះស្រាយផ្ទុយគ្នាក្តី តែមិនមានសំអាងផ្លូវច្បាប់ណាមួយ ដែលអង្គបុរេជំនុំជម្រះបានដកស្រង់មកនោះបង្ហាញថា សហចៅក្រមស៊ើបអង្កេតមិនបានគោរពដោយមិនខ្វល់ខ្វាយពីភាពច្បាប់លាស់ និង ដោយមិនសមហេតុផល ពីបទប្បញ្ញត្តិគតិយុត្តិរបស់ អ.វ.ត.ក. ឬ ការសម្រេច ឬ ការបំពេញកិច្ចដោយខុសឆ្គងនោះឡើយ។

៥. យ៉ាងរាក់កំផែល អង្គបុរេជំនុំជម្រះបានយល់ឃើញថា ជា"រឿងប្លែក ដែលដីកាដំណោះស្រាយ ដាច់ដោយឡែកពីគ្នា ត្រូវបានចេញក្នុងថ្ងៃតែមួយ ជាភាសាតែមួយ ដោយមានការប្រកាសរួមគ្នា ដោយសហចៅក្រមស៊ើបអង្កេតទាំងពីរថា ពួកគាត់បានព្រមព្រៀងគ្នា លើការចេញដោយខុសច្បាប់ នូវដីកាដំណោះស្រាយផ្ទុយគ្នា និង ដាច់ដោយឡែកពីគ្នា"[17] ហើយអះអាងដោយមិនត្រឹមត្រូវថា សហចៅក្រមស៊ើបអង្កេត បានផ្តល់ "សំអាងហេតុតិចតួចគួរឱ្យកត់សម្គាល់ ដោយលើកឡើងតែត្រឹមសេចក្តីសម្រេចកន្លងមករបស់ពួកគាត់ត្រឹមតែពីរប៉ុណ្ណោះ"[18]។ សេចក្តីសម្រេចកន្លងមកទាំងពីរនោះ ដែលអង្គបុរេជំនុំជម្រះបាន "បង្កើតឡើងវិញ ជាសម្រង់យ៉ាងធំ"[19] បានបង្ហាញដោយជាក់ច្បាស់អំពីសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត៖ ក្របខណ្ឌ អ.វ.ត.ក. មិនបានតម្រូវឱ្យសហចៅក្រមស៊ើបអង្កេត ប្តឹងទៅអង្គបុរេជំនុំជម្រះអំពីការខ្វែងយោបល់របស់ខ្លួនឡើយ។ ទោះបីជាអង្គបុរេជំនុំជម្រះ អាចមិនយល់ស្របជាមួយសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត តែ

---

[15] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៧។

[16] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៥។

[17] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៧។

[18] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៦។

[19] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ៨៥-៨៧ (ការដកស្រង់ខាងក្នុង ត្រូវបានលុបចោល)។

មិនមានអ្វីដែលអាចបង្ហាញពីការព្រមព្រៀងគ្នាខុសសីលធម៌ ដូចដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះឡើយ។

៦. ដោយមិនសមហេតុផល អង្គបុរេជំនុំជម្រះបានយល់ឃើញថា "កំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេត បានបង្កផលប៉ះពាល់ដល់ប្រព័ន្ធទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ"[20] ហើយក្រៅពីការរំលោភបំពាន ទៅលើក្របខណ្ឌរបស់ អ.វ.ត.ក. ហើយនោះ "*ការអនុវត្តដោយខុសឆ្គង* របស់សហចៅក្រមស៊ើបអង្កេត អាចស្មើនឹងការបដិសេធយុត្តិធម៌" ដោយសារតែអង្គបុរេជំនុំជម្រះ "មិនអាចមិនពិចារណាថា ពួកគាត់ប្រហែលមានចេតនាធ្វើឱ្យបរាជ័យដល់គោលជំហរដើម ហើយរំខានដល់សិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ"[21]។ ចាប់តាំងពីពេលណាមក ដែលការគោរពតាមការបកស្រាយទៅលើវិធាន ដែលទាញចេញពីការវិភាគដោយឯករាជតាមផ្លូវតុលាការ ជាការឆ្លុះបញ្ចាំងនូវ*ការអនុវត្តដោយខុសឆ្គង* ដែលជាការកំណត់លក្ខណៈ មានចេតនាធ្វើឱ្យមានរបួសដល់វិជ្ជាជីវៈនោះ?

៧. ជាការមិនគួរឱ្យជឿ អង្គបុរេជំនុំជម្រះបានបន្តតាមផ្លូវដដែល ដោយអះអាងថា "មិនត្រឹមតែជាឧទាហរណ៍ដាច់តែឯងប៉ុណ្ណោះទេ ប៉ុន្តែសកម្មភាពរបស់ពួកគាត់ នៅក្នុងករណីនេះ គាំទ្រនូវទម្រង់មួយ ដែលសហចៅក្រមស៊ើបអង្កេតបានអនុម័តយកដោយច្បាស់លាស់ ក្នុងការដោះស្រាយជាមួយបណ្តាសំណុំរឿងចុងក្រោយទាំងអស់ នៅក្នុងបញ្ជីសំណុំរឿងរបស់ អ.វ.ត.ក."[22] និង "កត់សម្គាល់ដោយការសោកស្តាយថា តាមការយល់ដឹង និង បទពិសោធន៍របស់ខ្លួន មិនដែលធ្លាប់មានសំណុំរឿងព្រហ្មទណ្ឌណា នៅក្នុងប្រវត្តិសាស្ត្រនៃប្រព័ន្ធច្បាប់អន្តរជាតិ និង ប្រព័ន្ធច្បាប់ជាតិដទៃទៀត ដែលបញ្ចប់ដោយការចេញសេចក្តីសម្រេចផ្ទុយគ្នាចំនួនពីរក្នុងពេលដំណាលគ្នា ហើយចេញដោយការិយាល័យចៅក្រមតែមួយនោះទេ"[23]។ ប្រសិនបើ អ.វ.ត.ក. បានអនុម័តយកនីតិវិធីប្រព័ន្ធច្បាប់ស៊ីវិល តាមគំរូបារាំងធម្មតានោះ ការអះអាងរបស់អង្គបុរេជំនុំជម្រះ អាចមានកម្លាំងទំនាញ។ ប៉ុន្តែដោយមើលឃើញថា អ.វ.ត.ក. គឺមានលក្ខណៈទាំងចម្រុះ និង *វិសាមញ្ញ (sui generis)* នោះកម្រិតនៃកំហុសឆ្គងនៅក្នុងវិធានផ្ទៃក្នុង ដែលមិនច្បាស់លាស់តិចតួចនោះ គឺអាចកើតឡើង។ ដោយសន្និដ្ឋានពីកំហុសផ្នែកអង្គច្បាប់ធ្ងន់ធ្ងន់ និង ជាក់ច្បាស់ដោយចេតនា នោះ អង្គបុរេជំនុំជម្រះបានអនុវត្តហួសដែនសមត្ថកិច្ចហើយ។

---

[20] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៨។

[21] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៨។

[22] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៨។

[23] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៩។

៨. ដោយមិនចាំបាច់ និង មិនមែនជាការចំអកតិចតួចនោះ បន្ទាប់ពីបានសម្រេចជាឯកច្ឆន្ទ លើការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា ថាខុសច្បាប់ហើយនោះ អង្គបុរេជំនុំជម្រះបែរជាបំបែកចេញពីគ្នាទៅតាមក្រុមជាតិ និង ក្រុមអន្តរជាតិរៀង១ខ្លួន ដោយមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះ សម្រេចផ្តល់ការពេញចិត្តចំពោះដីកាដំណោះស្រាយតាមជម្រើសរបស់ខ្លួនទៅវិញ[24]។ ដោយដឹងអំពីសិទ្ធិអំណាចរបស់ខ្លួនក្នុងការស៊ើបអង្កេត និង ចេញដីកាដំណោះស្រាយដែលកែប្រែ តែអង្គបុរេជំនុំជម្រះដោយមិនគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធមិនអនុវត្តមុខងាររបស់ខ្លួន ដោយ "ផ្តល់នូវការសម្រេចស្ថាពរជាក់ស្តែង" លើផលវិបាកនៃការប្រកាសថា ការចេញដីកាដំណោះស្រាយពីរគឺខុសច្បាប់[25]។

៩. ដូចនៅក្នុងរឿងក្តី ០០៤/២ ទោះបីជាប្រើប្រាស់ស្នៀតផ្សេងក្តី តែចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះបានយល់ឃើញថា គប្បីបញ្ជូនសំណុំរឿង ០០៣ "ទៅតម្កល់ទុកនៅបណ្ណាសារនៃ អ.វ.ត.ក."[26]។ ពួកគេបានផ្តល់សំអាងហេតុថា អង្គបុរេជំនុំជម្រះមិនអាចអនុវត្តយន្តការដោះស្រាយជម្លោះនៅក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុងបានទេ ដោយសារតែសហចៅក្រមស៊ើបអង្កេតបានយល់ស្របគ្នាមិនបញ្ជូនការខ្វែងយោបល់របស់ខ្លួនមកអង្គបុរេជំនុំជម្រះ "ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នាត្រូវតម្កល់ទុកជាបានការដូចគ្នា មានសុពលភាពដូចគ្នា"[27] ដោយផ្អែកតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត មានឋានៈស្មើគ្នា ហើយដោយយោងទៅតាមគោលការណ៍សច្ចធារណ៍នៃនិរទោស "ច្បាប់ពុំអនុញ្ញាតឱ្យ អ.ប.ជ. សម្រេចថា កិច្ចរបស់សហចៅក្រមស៊ើបអង្កេតណាម្នាក់មានឧត្តមភាពនោះទេ"[28] ព្រោះ "ដីកាដំណោះស្រាយទាំងពីររក្សាបាននូវតម្លៃស្មើគ្នាដដែល"[29]។

[24] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១១១-១១៨, ១១៩-៣៥៨។

[25] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦១។

[26] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១១៨។

[27] កំណត់សម្គាល់៖ ហាក់ដូចជាមានការខុសគ្នាក្នុងការបកប្រែនៅក្នុង កថាខណ្ឌ ១១៥។ បើតាមការបកប្រែក្រៅផ្លូវការ គឺថា "ដីកាដំណោះស្រាយទាំងពីរ មានតម្លៃដូចគ្នា និង មានសុពលភាពដូចគ្នា"។ មិនមានភាពច្បាស់លាស់ថាតើចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ សម្រេចថាដីកាដំណោះស្រាយទាំងពីរ មានសុពលភាព បើទោះបីជាបានចេញដោយខុសច្បាប់ក្តី ឬថាតើពួកគេសម្រេចថា ដីកាដំណោះស្រាយទាំងពីរ មាន*តម្លៃ*ដូចគ្នា តាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក.។

[28] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១១៣-១១៦។

[29] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១១៧។

១០. ប្រហែលគ្នានឹងជំហរនៅក្នុងរឿងក្ដី ០០៤/២ បើទោះបីជាបានប្រកាសអំពីចេតនាអាក្រក់ និង កំហុសឆ្គងដែលមិនសមស្របក្ដី បើទោះបីជាបានថ្កោលទោសចំពោះការព្រមព្រៀងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ ក្នុងពេលជាមួយនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហការីជាតិគាត់ក្ដី និង បើទោះបីជាបានប្រកាសថា ការចេញដីកាដំណោះស្រាយពីរ គឺជាការខុសច្បាប់ក្ដី ក៏ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានប្រកាសថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានសុពលភាព ហើយដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ *ហួសពីសមត្ថកិច្ច*[30]។ ទោះបីជាពាក្យពេចន៍បែបឆន្ទានុសិទ្ធិ នៅក្នុងវិធាន ៧២(២) នៃវិធានផ្ទៃក្នុងក្ដី ក៏ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានផ្ដល់សំអាងហេតុថា សហចៅក្រមស៊ើបអង្កេត តម្រូវឱ្យងាកទៅរកយន្តការដោះស្រាយជម្លោះ មុនពេលចេញដីកាដំណោះស្រាយ[31]។

១១. ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានប្រកាសថា "គោលការណ៍នៃការបន្តស៊ើបអង្កេត តាមផ្លូវតុលាការនេះ គ្រប់គ្រងលើបញ្ហាដែលនៅចំពោះមុខនេះ" ប៉ុន្តែមិនបានដកស្រង់សំអាងផ្នែកផ្លូវច្បាប់ដែលលើកឡើងថា គោលការណ៍នេះពង្រីកហួសដំណាក់កាលដីកាដំណោះស្រាយឡើយ[32]។ ដោយអះអាងថា "ការស្នើចេញដីកាសម្រេចលើកលែងចោទប្រកាន់" របស់សហចៅក្រមស៊ើបអង្កេតជាតិ "គ្រាន់តែជាការកំណត់ប្រភេទផ្សេងនៃការខ្វែងយោបល់របស់សហចៅក្រមស៊ើបអង្កេតជាតិ ទៅលើការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ" (បើទោះបីជាសហចៅក្រមស៊ើបអង្កេតជាតិ បានចេញ*ដីកា*សម្រេចលើកលែងចោទប្រកាន់ និង មិនមែនគ្រាន់តែស្នើឡើងនូវដីកាសម្រេចលើកលែងចោទប្រកាន់នោះឡើយ) [33] ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បង្កើតល្បិចថ្លឹនភ្នែក (conjured up a slight-of-hand fix)៖ ចាត់ទុកដោយប្រសិទ្ធភាពថា ដីកាដំណោះស្រាយទាំងពីរ គឺជាការខ្វែងយោបល់គ្នា ដែលបានចុះបញ្ជី ដូចជាថា ពួកគេត្រូវបានដាក់តាមវិធាន ៧២(២) នៃវិធានផ្ទៃក្នុង បោសសម្អាតនូវភាពខុសច្បាប់ និង ធ្វើឱ្យដំណើរការនូវគោលជំហរដើម ក្នុងវិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង ដើម្បីយល់ឃើញថា មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះដែលមានសុពលភាព[34] ។

---

[30] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ២៥៩។

[31] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ២៥៦-២៥៨។

[32] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ២៥៦។

[33] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ២៥៦-២៥៨។

[34] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ២៥៨-២៦២។

១២. ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានវាយលុកយ៉ាងខ្លាំងទៅលើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយសារមិនសម្លឹងឃើញមានប្រយោជន៍អ្វីហួស ក្រៅតែដើម្បីបំពេញចិត្តសុខដុមខ្លួនឯង ដែលទាញចេញពីការលើកឡើង*តាមការផ្តួតផ្តើមគំនិតដោយខ្លួនឯង* ថាខ្លួនឯងត្រឹមត្រូវ នូវបញ្ហាធម្មតាៗ ដូចជា[35] ៖

ក. តាមតែអំពើចិត្ត ប្រតិបត្តិតាមសេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ដកហូតពីភាគីនានានូវរយៈពេល ១៥ ថ្ងៃ ក្នុងការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ បើទោះបីជាគ្មានភាគីណាមួយបានប្តឹងឧទ្ធរណ៍ ឬ ស្នើសុំឱ្យមានការពិចារណាឡើងវិញលើសេចក្តីជូនដំណឹងលើកទីពីរអំពីការបិទការស៊ើបសួរក្តី[36]។

ខ. ដោយមិនយកចិត្តទុកដាក់ នៅក្នុងការឱ្យដំណឹងពីសំណុំរឿង និង ការបង្កើតនូវការពន្យាពេលហួសហេតុ ដោយរង់ចាំអស់រយៈពេលពីរខែ បន្ទាប់ពីការចេញសេចក្តីជូនដំណឹងលើកទីពីរតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ក្នុងការបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា[37] បើទោះបីជាសហព្រះរាជអាជ្ញាមានសិទ្ធិចូលពិនិត្យសំណុំរឿង តាមប្រព័ន្ធអេឡិចត្រូនិក និង មិនមានការរំខាន នៅក្នុងការព្រាងដីកាសន្និដ្ឋានស្ថាពររបស់ពួកគាត់ក៏ដោយ។

គ. ការខកខានមិនបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួន នៅក្នុងពេលវេលាសមស្រប បើទោះបីជាសហចៅក្រមស៊ើបអង្កេតបានបញ្ចប់ដីកាដំណោះស្រាយរបស់ពួកគេ នៅក្នុងរយៈ

---

[35] ជាការគួរឱ្យសោកស្តាយ សហមេធាវីយល់ឃើញថា ចាំបាច់ត្រូវរំឭកសារជាថ្មី ពីចំណូលចិត្តរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ក្នុងការប្រកាន់យកបុព្វហេតុ ដែលរៀបចំឡើង ដើម្បីជំទាស់ដោយគ្មានសុភវិនិច្ឆ័យ ដូចជាការខំមិនព្រលែងលើបញ្ហា ដែលមិនមែនការកត្តាកំណត់ ឬមិនសំខាន់ចំពោះបណ្តឹងឧទ្ធរណ៍ ក្នុងគោលបំណងតែមួយគត់ គឺបង្អាក់បង្ខូចសហចៅក្រមស៊ើបអង្កេត ជាពិសេសសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ពាក្យជៀមដាម និងការចោទប្រកាន់បក នៅក្នុងករណីនេះ ធ្វើឱ្យនឹកឃើញទៅដល់រឿងក្តី ០០៤/១ និង០០៤/២។ *សូមមើល* សំណើរបស់ មាស មុត សុំអនុញ្ញាតដាក់សារណាបន្ថែម ទៅលើចម្លើយរបស់ខ្លួន តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ២០១០ ឯកសារ D256/12 កថាខណ្ឌ ១១, ១៦-១៩ កំណត់សម្គាល់ ៣៩។ សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ ឯកសារ D267/27 ("សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់គាត់") កថាខណ្ឌ ១៣-១៥។

[36] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៣៩-១៤១។

[37] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៤២ -១៤៣។

ពេលប្រាំបីខែ បន្ទាប់ពីមានចម្លើយរបស់មេធាវីការពារក្តី តបទៅនឹងដីកាសន្និដ្ឋានស្ថាពរ[38] ហើយអង្គបុរេជំនុំជម្រះ បានចំណាយរយៈពេល ១៦ ខែ ដើម្បីចេញសេចក្តីពិចារណារបស់ខ្លួន ដោយមិនមានការស៊ើបអង្កេតរឿងក្តី ដូចដែលខ្លួនមានសិទ្ធិអំណាចនោះ[39]។

ឃ. ដោយខុសឆ្គង"តម្កល់គោលការណ៍កំណត់ប្រភេទនៃភស្តុតាង តាមឋានានុក្រម និង តាមទម្រង់ច្បាប់ ដោយផ្អែកលើប្រភពជាជាងលើខ្លឹមសារ"[40] បើទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានវាយតម្លៃទៅលើភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង ហើយមិនបានបង្កើតប្រភេទតាមឋានានុក្រម ឬ ដកចេញនូវប្រភេទនៃភស្តុតាងផ្អែកលើប្រភព និង វាយតម្លៃដោយសេរីទៅលើតម្លៃនៃភស្តុតាង ទៅតាមមូលដ្ឋានករណីជាក់ស្តែង និង ពិចារណាដោយសមហេតុផល ទៅលើយុត្តិសាស្ត្រ ដែលមានកំណត់ជាក់ច្បាស់ ដែលពាក់ព័ន្ធប្រភេទនៃភស្តុតាងក្តី[41]។

ង. ការខកខានមិនបានបង្គាប់ឱ្យឃុំខ្លួនលោក មាស មុត មុនពេលជំនុំជម្រះ បើទោះបីជាលោក មាស មុត គោរពទៅតាមលក្ខខណ្ឌ នៃការធានាអះអាងរបស់គាត់ ជាមួយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានដាក់ជូនគាត់ នៅពេលដែលគាត់ត្រូវបានចោទប្រកាន់ក្តី[42]។

១៣. សហចៅក្រមស៊ើបអង្កេតជាតិ ក៏គេចមិនផុតពីការស្តីបន្ទោសដោយអយុត្តិធម៌យ៉ាងខ្លាំងពីចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ដោយយល់ឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់ "ជាការប៉ុនប៉ងមួយ ដើម្បីគេចចេញពីនីតិវិធី ដែលតម្រូវចាំបាច់ សម្រាប់ការខ្វែងយោបល់គ្នា" គឺ "ជាការប៉ុនប៉ងដោយឥតអៀនខ្មាស់ ក្នុងការគេចវេសទាំងស្រុង ពីលក្ខខណ្ឌតម្រូវជាចាំបាច់ និង សំខាន់នេះ ដែលធ្វើឱ្យខូចខាតដល់អត្ថបទគតិយុត្តិ ដែលជាមូលដ្ឋានរបស់ អ.វ.ត.ក." "ហួសដែនសមត្ថកិច្ច ... ដោយសារនេះគឺជាប៉ុនប៉ង ធ្វើឱ្យខូចខាតគោលជំហរដើម ដែលមានចែងនៅក្នុងក្របខណ្ឌគតិយុត្តិ

[38] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៤៧។

[39] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៣០។

[40] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៥៦។

[41] ដីកាដំណោះស្រាយ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 កថាខណ្ឌ ១១៨-១៤៨។ នេះជាឧទាហរណ៍មួយទៀតនៃការយល់ឃើញខុស ឬការបកស្រាយខុសដោយចេតនារបស់អង្គបុរេជំនុំជម្រះ ទៅលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមិនមែនជាកត្តាកំណត់ ឬកត្តាសំខាន់ចំពោះបណ្តឹងឧទ្ធរណ៍។ *សូមមើល រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/០២/០៧-០៩-២០០៩-អវតក/កសចស ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 កថាខណ្ឌ ៣៧។

[42] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ៣៤៥-៣៥៨។

របស់ អ.វ.ត.ក."[43] បើទោះបីជាសហចៅក្រមស៊ើបអង្កេតទាំងពីរ បានព្រមព្រៀងគ្នា មិនបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ និង ចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា ក្នុងពេលជាមួយគ្នាក្តី។

១៤. សហចៅក្រមស៊ើបអង្កេតទាំងពីរ ត្រូវបានស្តីបន្ទោសដោយមិនចាំបាច់ ចំពោះការរំលោភបំពានទៅលើសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ និង "ជម្រុញឱ្យមានការពន្យារពេលហួសហេតុបន្ថែមទៀត នៅក្នុងដំណើរការនីតិវិធីសំណុំរឿង ០០៣ ទាំងមូលតែម្តង" ដោយដាក់ដីកាដំណោះស្រាយរបស់ខ្លួនតែមួយភាសាប៉ុណ្ណោះ[44] បើទោះបីជាតាមការធ្វើបែបនេះក្តី ក៏សហចៅក្រមស៊ើបអង្កេតបានផ្តល់ពេលវេលាបន្ថែមដល់ភាគី ដើម្បីត្រៀមរៀបចំទម្រង់ករណ៍បណ្តឹងឧទ្ធរណ៍របស់ពួកគេ ព្រោះពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងទាំងពីរភាសាក្តី[45]។

១៥. ទោះបីជាអង្គជំនុំជម្រះតុលាការកំពូល បានគូសបញ្ជាក់ពីឧបាស្រ័យដែលអង្គបុរេជំនុំជម្រះអាចប្រើប្រាស់ ដើម្បីដោះស្រាយដីកាដំណោះស្រាយខុសច្បាប់ ផ្អែកលើការប្រកាសដោយផ្ទាល់របស់អង្គបុរេជំនុំជម្រះក្តី គឺការចេញដីកាដំណោះស្រាយដែលបានកែប្រែ និង ស៊ើបអង្កេតរឿងក្តីដោយខ្លួនឯងក្តី[46] តែចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ មិនបានប៉ុនប៉ងនឹងគោរពតាមឧបាស្រ័យទាំងអស់នេះទេ។ ផ្ទុយទៅវិញ ពួកគេ ដោយគិតគូរទុក បានជ្រើសរើសធ្វើការវាយលុកទៅលើអង្គជំនុំជម្រះតុលាការកំពូលថា៖

ក. ការបង្កើត "ជំហានលោតផ្លោះគួរឱ្យកត់សម្គាល់ទៅដល់សំអាងហេតុមួយ" ដោយ "ហាក់ដូចជានិយាយពាំត្រណោត ចំពោះការសម្រេចរបស់អង្គបុរេជំនុំជម្រះដែលថា សកម្មភាពរបស់សហចៅក្រមស៊ើបអង្កេត ក្នុងកាចេញដីកាដំណោះស្រាយគឺខុសច្បាប់ ដោយមានការសន្និដ្ឋានថា ដីកាដំណោះស្រាយគឺ "មោឃៈ" ដោយសារបែបនេះ"[47] បើទោះបីជាយោងទៅតាមវិធាន

---

[43] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ២៦០, ២៦២។

[44] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៤៨។

[45] មាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ នៅចំពោះមុខ អ.វ.ត.ក.។

[46] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦១ ដែលដកស្រង់សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៣០។

[47] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ២៧៣។

នៃការបកស្រាយរបស់ប្រព័ន្ធច្បាប់ស៊ីវិល នីតិវិធីព្រហ្មទណ្ឌកម្ពុជាជាធរមាន និង វិធាននីតិវិធី ដែលបានកំណត់នៅកម្រិតអន្តរជាតិ នៅពេលដែលចៅក្រមបំពេញកិច្ចដោយ*ខុសច្បាប់* ក្នុងការចេញដីកាដំណោះស្រាយ ផលវិបាកផ្នែកផ្លូវច្បាប់គឺថា ដីកាដំណោះស្រាយត្រូវតែមោឃៈ និងទុព្វល[48]។

ខ. ការធ្វើ "សន្និដ្ឋានសរុបជារួម ដោយមិនមានការបង្ហាញដោយសមហេតុផល" ពីហេតុដែលអនីត្យានុកូលភាពផ្នែកនីតិវិធីនៃសកម្មភាពរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការបង្កើតដីកាដំណោះស្រាយ "នឹងបណ្តាលឱ្យមានការខូចខាតទាំងស្រុង ទៅលើដីកាដំណោះស្រាយទាំងពីរដែលមានបញ្ហា" ព្រោះកំហុសឆ្គងនីតិវិធី ត្រូវតែបណ្តាលឱ្យមាន "លទ្ធផលមិនយុត្តិធម៌ទាំងស្រុង នៅក្នុងដំណើរការនីតិវិធីរបស់តុលាការ" ទើបនាំទៅរកការកែប្រែសាលក្រមនោះ[49] បើទោះបីជាដីកាដំណោះស្រាយ មិនមែនជា "សាលក្រម" និង បើទោះបីជាអង្គបុរេជំនុំជម្រះយល់ឃើញថា អនីត្យានុកូលភាពផ្នែកនីតិវិធីនេះគឺ "ក្រៅពីការរំលោភបំពានទៅលើគោលការណ៍ជាមូលដ្ឋាននៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក" ហើយ វា"បានបង្កផលប៉ះពាល់ដល់ប្រព័ន្ធទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ" និង "អាចបានតម្លៃស្មើនឹងការបដិសេធយុត្តិធម៌"[50]។

គ. "ការធ្វើអ្វីមួយយ៉ាងប៉ិនប្រសប់ ដើម្បីជាលេសងាយស្រួលមួយ ក្នុងការធ្វើឱ្យដំណើរការនីតិវិធីឈានទៅដល់ការបញ្ចប់" "បុរេលក្ខខណ្ឌតម្រូវផ្នែករដ្ឋបាល អំពីការជូនដំណឹង និង ការបញ្ជូនដែលរងចំណោទ"[51] - បើទោះបីជាតាមក្របខណ្ឌ អ.វ.ត.ក. ការជូនដំណឹង និង ការបញ្ជូនសំណុំរឿងត្រូវបានតម្រូវឱ្យមាន ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូង អាចទទួល និង ចាត់សកម្មភាព ហើយអង្គបុរេជំនុំជម្រះ មិនបានជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួនដល់អង្គជំនុំជម្រះសាលាដំបូងឡើយ[52]។

---

[48] *សូមមើល* សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់គាត់ កថាខណ្ឌ ៣១។

[49] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កំណត់សម្គាល់ ៦០៩។

[50] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៨។

[51] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កំណត់សម្គាល់ ៥៩៥។

[52] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៤៩។

(ឃ) ការយល់ឃើញថាមិនចាំបាច់ "ក្នុងការវិភាគលើអត្ថបទនៃសេចក្តីសម្រេចជាក់ស្តែងរបស់អង្គបុរេជំនុំជម្រះ ដើម្បីបញ្ជាក់បំភ្លឺ... តើអង្គបុរេជំនុំជម្រះបានយល់ឃើញជាឯកច្ឆន្ទឬទេ ថា ដីកាដំណោះស្រាយទាំងពីរ គឺមោឃៈ និង ទុព្វលនោះ"[53] បើទោះបីជាគ្មានអ្វីសោះ នៅក្នុងសំអាងហេតុរួម និង ផ្នែកសម្រេចសេចក្តី នឹងនាំឱ្យអ្នកអាន ដែលមានមូលហេតុសមស្រប អាចសន្និដ្ឋានថា ដីកាដំណោះស្រាយទាំងពីរ មានសុពលភាពនោះ។

(ង) ការបញ្ចប់តាមអំពើចិត្ត នូវរឿងក្តី ០០៤/២ ដោយមិនមានដីកាដំណោះស្រាយ ដែល "មិនបាននាំឱ្យមានភាពច្បាស់លាស់ ភាពស្ថាពរ និង សច្ចភាពគតិយុត្តិ"[54] បើទោះបីជាអង្គបុរេជំនុំជម្រះជ្រើសរើសមិនអនុវត្តនូវឧបាស្រ័យណាមួយ ដែលអាចមានតាមច្បាប់ ហើយជ្រើសរើសទុកឱ្យរឿងក្តីស្ថិតនៅក្នុងការជាប់គាំងតាមផ្លូវតុលាការ។

(ច) ការធ្វើសេចក្តីសម្រេចដោយមិនពិនិត្យមើលភស្តុតាង "តាមរយៈសេចក្តីណែនាំបញ្ចប់ ដែលមានលក្ខណៈជាអនុក្រិត្យទៅវិញ"[55] បើទោះបីជាបញ្ហាដែលលើកឡើង ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងបណ្តឹងឧទ្ធរណ៍ភ្លាមៗរបស់ខ្លួន ពាក់ព័ន្ធតែនឹងបញ្ហាគតិយុត្តិក្តី។

(ឆ) ការបកស្រាយខុសនូវ សេចក្តីសម្រេចជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ លើការយល់ស្របគ្នាខុសច្បាប់ រវាងសហចៅក្រមស៊ើបអង្កេត "ក្នុងការគេចចេញពីនីតិវិធីដោះស្រាយការខ្វែងយោបល់" ដោយខកខានមិនបានទទួលស្គាល់ថា ការស៊ើបអង្កេតត្រូវធ្វើបន្ត[56] បើទោះបីជាមិនមានដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដែលមានសុពលភាព ដែលត្រូវបន្តនៅពេលដែលប្រកាសថា ដីកាដំណោះស្រាយទាំងនោះខុសច្បាប់។

(ជ) ការ"ពោលបញ្ឆិតបញ្ឆៀងថា ការបិទបញ្ចប់ដំណើរការនីតិវិធីគឺសមល្មមហើយ ដោយការពិចារណាដល់ការស៊ើបអង្កេតយូរអស់រយៈពេលដប់បីឆ្នាំ ... [ដែល] មិនចាត់ជាមូលដ្ឋានគតិយុត្តិដែលសុពល ដោយសារតែក្របខណ្ឌគតិយុត្តិ អ.វ.ត.ក. មិនបានចែងអំពីពេលវេលាកំណត់ជាក់លាក់ ដែលអង្គជំនុំជម្រះតុលាការកំពូល អាចបិទបញ្ចប់សំណុំរឿង តាមរយៈដីកា

[53] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ២៧៤។

[54] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ២៧៩។

[55] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ២៨០។

[56] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ២៧៥។

សម្រេចបែបប្រតិបត្តិនោះ”[57] បើទោះបីជាជនជាប់ចោទទាំងអស់នៅ អ.វ.ត.ក. ត្រូវបានទទួលសិទ្ធិទទួលបានការជំនុំជម្រះក្តី “ដោយមិនមានការពន្យាពេលមិនសមហេតុផល”ក្តី[58]។

១៦. នាពេលនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បានអំពាវនាវដល់សហចៅក្រមស៊ើបអង្កេត ឱ្យចាត់វាល់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ ដើម្បីបង្គាប់ឱ្យផ្នែកគ្រប់គ្រងតុលាការ “បញ្ជូនសេចក្តីពិចារណានេះ រួមទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង និង អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង ចូលមើលសំណុំរឿង ដែលនៅសេសសល់តាមប្រព័ន្ធអេឡិចត្រូនិក”[59]។ ភ្លាមៗ បន្ទាប់ពីដាក់សំណើនេះ ស.ព.អ. បានស្នើសុំពន្យារពេលវេលាដាក់បញ្ជីឈ្មោះសាក្សី និង អ្នកជំនាញរបស់ខ្លួន តាមវិធាន ៨០ នៃវិធានផ្ទៃក្នុង[60] ដោយក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ជូនយោបល់ដល់ភាគីថា “អង្គជំនុំជម្រះសាលាដំបូង មិនត្រូវបានជូនដំណឹងអំពី “សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ” ហើយក៏មិនបានទទួលសំណុំរឿងដែរ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង មិនទទួលលិខិតទំនាក់ទំនងណាមួយ ពីភាគីឡើយ (សូមមើលផងដែរ វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង”[61]។

១៧. *បានជួបប្រទះសាជាថ្មីម្តងទៀតហើយ* (Déjà vu all over again)[62]។

## II. ភាពអាចទទួលយកបាន

១៨. សំណើរបស់ ស.ព.អ. មិនអាចទទួលយកបានទេ ព្រោះ៖ (ក) ដីកាដំណោះស្រាយទាំងពីរមោឃៈ និង ឥតបានការ ដូច្នេះហើយមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបន្តដំណើរការទៅមុខឡើយ (ខ) ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ មិនបានផ្តល់សំអាងហេតុ ឬ សំអាងផ្លូវច្បាប់សម

[57] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កំណត់សម្គាល់ ៦២១។

[58] មាត្រា ១២(២), ១៣(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ៣៥ថ្មី(គ) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

[59] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១។

[60] សារអេឡិចត្រូនិករបស់ Brenda J. Hollis ចំណងជើង “សំណើសុំបន្ថែមពេលវេលាដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញស្របតាមវិធាន ៨០” ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០២១។

[61] សារអេឡិចត្រូនិករបស់លោក លឹម ស៊ុយហុង ចំណងជើង “ យោង៖ សំណើសុំបន្ថែមពេលវេលាដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ស្របតាមវិធាន ៨០” ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២១។

[62] ជាសម្តីរបស់កីឡាករ baseball អាមេរិកឈ្មោះ Yogi Berra។

ស្រប សម្រាប់ការដាកចេញពីការវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូលទេ (គ) អង្គបុរេជំនុំជម្រះនៅតែមានសំណុំរឿងក្តីនៅក្នុងដៃ និង ទទួលខុសត្រូវក្នុងការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង (ឃ) អង្គបុរេជំនុំជម្រះមិនបានសម្រេចដោយសំឡេងភាគច្រើនលើសលប់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព និង មិនបានជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូង អំពីសេចក្តីពិចារណារបស់ខ្លួន អនុលោមតាមវិធាន ៧៩(១) នៃវិធានផ្ទៃក្នុងនៅឡើយទេ។

១៩. *ដីកាដំណោះស្រាយទាំងពីរគឺមោឃៈ និង ឥតបានការ* ៖ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អនុភាពគតិយុត្តិនៃការសម្រេចជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ ដែល"**ប្រកាស** ថា ការចេញដីកាពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ដោយរំលោភបំពានលើក្របខណ្ឌច្បាប់របស់ អ.វ.ត.ក." គឺថាដីកាដំណោះស្រាយទាំងពីរត្រូវទុកជាមោឃៈ និង ឥតបានការ[63]។ អង្គជំនុំជម្រះតុលាការកំពូល បានផ្តល់សំអាងហេតុថា ដីកាដំណោះស្រាយ "ដែលជាលទ្ធផលនៃ*ចំណាត់ការខុសច្បាប់ និង ពុំត្រឹមត្រូវតាមច្បាប់*" គឺឥតបានការ អញ្ចឹងហើយ ទើបមិនអាចបង្កើតផលវិបាក ឬ លទ្ធផលត្រឹមត្រូវតាមច្បាប់[64] បើទោះបីជាអង្គជំនុំជម្រះ "ទទួលស្គាល់ថា គោលដៅនៃយន្តការដោះស្រាយការខ្វែងយោបល់គ្នា គឺដើម្បី "ទប់ស្កាត់ភាពទាល់ច្រក មិនឱ្យភ្ជាត់ចេញពីដំណើរការនីតិវិធី ពីការបន្តដំណើរទៅរកការជំនុំជម្រះ""[65]។ ចំពោះបញ្ហា "ថាតើរឿងក្តីនេះឈានទៅជំនុំជម្រះក្នុងករណីពុំមានដីកាដំណោះស្រាយដែលសុពល" ដែរឬទេ អង្គជំនុំជម្រះតុលាការកំពូលបានថ្លែងថា "ចម្លើយប្រាកដណាស់គឺទេ"[66]។

២០. *គ្មានសំអាងហេតុសមស្របសម្រាប់ការដាកចេញ*៖ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ មិនបានផ្តល់សំអាងហេតុ ឬ សំអាងផ្លូវច្បាប់សមស្រប សម្រាប់ការដាកចេញពីការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងរឿងក្តី ០០៤/២។ អង្គជំនុំជម្រះតុលាការកំពូល ដោយកត់សម្គាល់ ពីការសម្រេចជាឯកច្ឆន្ទនៅក្នុងរឿងក្តី ០០៤/២ ដែលថា ខ្លួន "មានសិទ្ធិអំណាចក្នុងការចេញដីកាដំណោះស្រាយថ្មី ឬ កែប្រែដីកាដំណោះស្រាយនោះ" និង "នៅពេលបានទទួលដីកាលើកលែងចោទ

---

[63] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៥៣។

[64] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦៧, ៧១(v)។

[65] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦៨។

[66] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦៨។

ប្រកាន់ ដោយសារផលវិបាកនៃបណ្តឹងឧទ្ធរណ៍ ត្រូវស៊ើបអង្កេតរឿងក្តីដោយខ្លួនឯង"[67] បានយល់ឃើញថា "ការយល់ឃើញច្បាស់លាស់នេះ នឹងនាំឱ្យអ្នកវិភាគសមហេតុផល អាចសន្និដ្ឋានថា អង្គបុរេជំនុំជម្រះបានដឹងអំពីសិទ្ធិអំណាចរបស់ខ្លួន ក្នុងការធ្វើលើសពីការប្រកាសភាពខុសច្បាប់នៃស្ថានការណ៍ ដែលពាក់ព័ន្ធទៅនឹងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និង ចេញដីកាដំណោះស្រាយដែលសុពលរបស់ខ្លួនថ្មីមួយបាន"[68]។ ហេតុដូច្នេះ ប្រសិនបើអង្គបុរេជំនុំជម្រះ មិនបានដឹងអំពីជម្រើសដែលខ្លួនអាចអនុវត្ត នៅពេលចេញសេចក្តីពិចារណាក្នុងរឿងក្តី ០០៤/២ ដែលសូម្បី "អ្នកវិភាគសមហេតុផល" ប្រាកដជាបានសន្និដ្ឋានផ្សេងពីនេះ ដោយផ្អែកលើការប្រកាសផ្ទាល់របស់អង្គបុរេជំនុំជម្រះក្តី ក៏មិនមានការពន្យល់ណាមួយត្រូវបានផ្តល់ សម្រាប់ការបដិសេធដោយចេតនា នូវបណ្តាជម្រើសដែលខ្លួនអាចមាន ដូចដែលអង្គជំនុំជម្រះតុលាការកំពូល បានផ្តល់ព័ត៌មានយ៉ាងជាក់ច្បាស់នោះឡើយ។

២១. ទោះបីជាអង្គបុរេជំនុំជម្រះ បានវាយលុកដោយធ្វើពុតជាប្រកាន់ខ្លាំង ទៅលើសហចៅក្រមស៊ើបអង្កេត ដោយសារតែមិនគោរពតាមនីតិវិធីដែលមានក្តី ក៏ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានអនុវត្តលើស ដោយបកស្រាយដោយខុស នូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល និងខកខាន ៖

ក. មិនបានស្វែងយល់ថា វិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល នីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលនៅជាធរមាន និង វិធាននីតិវិធីដែលបានកំណត់នៅកម្រិតអន្តរជាតិ បានចែងថា នៅពេលដែលចៅក្រមមិនមានសិទ្ធិចេញសេចក្តីសម្រេចជាក់លាក់ណាមួយ សេចក្តីសម្រេចនោះត្រូវចាត់ទុកជាមោឃៈ និង ឥតបានការ[69]។

ខ. មិនបានញែកលក្ខណៈនៃដីកាដំណោះស្រាយឱ្យដាច់ពីលក្ខណៈនៃសាលក្រម ដោយទាញយកបទដ្ឋានពិនិត្យឡើងវិញ ដែលមិនសមស្របមកជាសំអាង សម្រាប់កំហុសនីតិវិធីលើបណ្តឹងឧទ្ធរណ៍[70]។

---

[67] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦១ ដែលដកស្រង់សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៤០-៤២។

[68] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦១។

[69] *សូមមើល* សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់គាត់ កថាខណ្ឌ ៣១។

[70] សេចក្តីពិចារណារបស់ អ.ជ.ប. ក្នុងរឿងក្តី ០០៣ កំណត់សម្គាល់ ៦០៩។

គ. មិនបានកត់សម្គាល់នៅក្នុងផ្នែករួមនៃសំអាងហេតុ ឃើញអ្វីចំពោះអនុភាពដែលថា ដីកាដំណោះស្រាយណាមួយ មានសុពលភាព និង នៅជាធរមាន[71]។

ឃ. មិនបានស្វែងយល់អំពីលក្ខណៈអង្គច្បាប់ (ដែលផ្ទុយពីអង្គហេតុ) នៃបញ្ហា ដែលត្រូវបានបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍ភ្លាមៗ របស់សហព្រះរាជអាជ្ញាអន្តរជាតិ និង បទដ្ឋានពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូល សម្រាប់កំហុសឆ្គងលើបណ្តឹងឧទ្ធរណ៍បែបនោះ[72]។

ង. មិនបានទទួលស្គាល់សិទ្ធិរបស់ជនត្រូវចោទ តាមវិធានផ្ទៃក្នុង ២១(៤) ក្នុងការទទួលបានដំណើរការនីតិវិធី "ដែលនាំមកនូវសេចក្តីសន្និដ្ឋានមួយក្នុងរយៈពេលមួយសមស្រប"[73]។ និង

ច. មិនបានស្វែងយល់ពីនីតិវិធីនៃការបញ្ជូន និង ប្រគល់ដំណឹង ដូចមានចែងនៅក្នុងក្របខណ្ឌរបស់ អ.វ.ត.ក.[74]។

២២. <u>*អង្គបុរេជំនុំជម្រះនៅតែមានសំណុំរឿងក្តីក្នុងដៃ៖*</u> អង្គបុរេជំនុំជម្រះត្រូវបានប្តឹងឱ្យទទួលរឿងក្តី និង ត្រូវទទួលខុសត្រូវក្នុងការផ្ទេរសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង។ ដោយការចេញដីកាដំណោះស្រាយ ភ្លាមៗនោះ សហចៅក្រមស៊ើបអង្កេត បាន*បំពេញតួនាទីរបស់ខ្លួនចប់សព្វគ្រប់ហើយ (functus officio)* [75]។ ដោយមានការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេត "លែងមានសិទ្ធិអំណាចលើរឿងក្តី ដែលបានប្តឹង ហើយនឹងលែងមានសិទ្ធិអំណាចលើគ្រប់ទិដ្ឋភាពនៃការស៊ើបអង្កេតលើរឿងក្តីនេះ"[76]។ សំណុំរឿងទាំងមូលត្រូវបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ ដោយមិនអាចប្រកែកតវ៉ា "អង្គជំនុំជម្រះទទួលបានសិទ្ធិអំណាច លើសំណុំរឿងទាំងមូល"[77] ដូច្នេះហើយ ត្រូវមាន "យុត្តាធិការចុងក្រោយលើការស៊ើបអង្កេត រួមទាំង

---

[71] សេចក្តីពិចារណារបស់ អ.ជ.ប. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ២៧៤។

[72] សេចក្តីពិចារណារបស់ អ.ជ.ប. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ២៨០។

[73] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ២៧៥។ *សូមមើលផងដែរ* វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

[74] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៤៩។

[75] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៣២ ដែលដកស្រង់ *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/០២/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 ("សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/១") កថាខណ្ឌ ៣៣។

[76] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១២៦។

[77] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១២៦, ១៣២។

យុត្តាធិការលើរាល់សំណើទាំងអស់ ទាក់ទងនឹងដំណាក់កាលមុនជំនុំជម្រះ បន្ទាប់ពីការិយាល័យសហចៅក្រមស៊ើបអង្កេត លែងមានសិទ្ធិទទួលសំណុំរឿង”[78]។ “អង្គជំនុំជម្រះសាលាដំបូង ដោយត្រឹមត្រូវតាមច្បាប់គឺត្រូវទទួលសំណុំរឿង ក្នុងករណីដែលអង្គបុរេជំនុំជម្រះបញ្ជូនសំណុំរឿងពាក់ព័ន្ធ ដោយអនុលោមតាមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក.”[79]។

២៣. *ដោយការខ្វះសំឡេងភាគច្រើនលើសលុប មិនអាចបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះបានទេ* ៖ អង្គបុរេជំនុំជម្រះមិនបានសម្រេច ដោយសំឡេងភាគច្រើនលើសលុបថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ដូច្នេះហើយ ទើបមិនបានជូនដំណឹង និង បញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង តាមវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។ ទោះបីជា ស.ព.អ. បានអះអាងថា មានការសម្រេចដោយសំឡេងភាគច្រើនលើសលុបថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានសុពលភាព[80] តែមិនមាននៅក្នុងសំអាងហេតុ និង ផ្នែកសម្រេចសេចក្តីរួម ចំពោះអនុភាពនេះទេ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា មតិយោបល់របស់ចៅក្រមនៃអង្គបុរេជំនុំជម្រះ លើសុពលភាពនៃដីកាដំណោះស្រាយ ដែលផ្ទុយគ្នា និង ដាច់ពីគ្នា “គឺជាការអនុវត្តដែលពុំចាំបាច់” ដោយសារតែ “មិនជាប់ពាក់ព័ន្ធទៀតថា អង្គបុរេជំនុំជម្រះ ពុំបានទទួលមតិភាគច្រើនលើសលុប ដែលតម្រូវក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ភាគី ប្រឆាំងនឹងដីកាដែលផ្ទុយគ្នា ដោយសារផ្នែកសេចក្តីពិចារណាលើផ្នែកនេះទៅជារឿងលែងចាំបាច់”[81]ហើយ។

២៤. ហេតុដូច្នេះ ដោយសារតែដីកាដំណោះស្រាយទាំងពីរត្រូវមោឃៈ និង លែងបានការ ដោយសារតែមិនមានសំអាងហេតុសមស្រប ក្នុងការងាកចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងរឿងក្តី ០០៤/២ ដោយសារតែអង្គបុរេជំនុំជម្រះ នៅកាន់សំណុំរឿងក្តីក្នុងដៃ និង ទទួលខុសត្រូវលើការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង និង ដោយសារតែអង្គបុរេជំនុំជម្រះមិនបានសម្រេចតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសំឡេងភាគច្រើនលើសលុប នោះសហចៅក្រមស៊ើបអង្កេត គួរយល់ថា សំណើរបស់ ស.ព.អ. មិនអាចទទួលយកបាន។

---

[78] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៣២។

[79] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៧១ (i)។

[80] សំណើរបស់ ស.ព.អ. កថាខណ្ឌ ២, ៥, ១២។

[81] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៥៣។

## III. ចម្លើយតបទៅនឹងសារណារបស់ ស.ព.អ.

២៥. ស.ព.អ. បានអះអាងដោយភាន់ច្រឡំថា អង្គបុរេជំនុំជម្រះបានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសំឡេងភាគច្រើនលើសលុប ហើយអង្គជំនុំជម្រះសាលាដំបូង ត្រូវទទួល ដោយស្វ័យប្រវត្តិ យក រឿងក្តី ០០៣ នៅពេលចេញសេចក្តីពិចារណារបស់ពួកគេ[82]។ ប្រធានអង្គបុរេជំនុំជម្រះ បាន ជូនដំណឹងទៅផ្នែកគ្រប់គ្រងតុលាការ និង ប្រធានការិយាល័យរដ្ឋបាល បន្ទាប់ពីមានសេចក្តីពិចារណា ក្នុងរឿងក្តី ០០៤/២ ថា "មានតែផ្នែកសម្រេចសេចក្តីរួម ដែលបានសម្រេចជាឯកច្ឆន្ទ និង ចុះហត្ថលេខាដោយចៅក្រមទាំងប្រាំនាក់ប៉ុណ្ណោះ ដែលមានអនុភាពអនុវត្ត។ មតិយោបល់ផ្ទាល់ខ្លួន របស់ចៅក្រមម្នាក់ៗ មិនមានអនុភាពអនុវត្តឡើយ"[83]។ ផ្នែកសម្រេចសេចក្តីរួមគ្នា មិននាំឱ្យអ្នក អានសមហេតុផល ធ្វើការសន្និដ្ឋានថា អង្គបុរេជំនុំជម្រះតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយ សំឡេងភាគច្រើនលើសលុបឡើយ។

២៦. ស.ព.អ. អះអាងដោយភាន់ច្រឡំនៅក្នុងកំណត់សម្គាល់ជើងទំព័រមួយថា អង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលដោយស្វ័យប្រវត្តិ ដោយសារតែដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបដិសេធដោយ សំឡេងភាគច្រើនលើសលុប ដូច្នេះហើយ សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចបញ្ជូនសេចក្តី ពិចារណា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង សំណុំរឿងដែលនៅសេសសល់[84]។ បើទោះបីជាសហ ចៅក្រមស៊ើបអង្កេត សម្រេចថា ដីកាដំណោះស្រាយទាំងពីរ *មិន*ត្រូវបានបដិសេធ ដោយសំឡេង ភាគច្រើនលើលសលុបរបស់អង្គបុរេជំនុំជម្រះក្តី តែដីកាដំណោះស្រាយទាំងពីរត្រូវមោឃៈ និង ឥត បានការ បើយោងតាមអង្គជំនុំជម្រះតុលាការកំពូល[85]។ ហើយបើទោះបីជាសហចៅក្រមស៊ើប អង្កេត មានសំអាងហេតុសមស្រប ក្នុងការងាកចេញពីការសម្រេចរបស់អង្គជំនុំជម្រះតុលាការ កំពូលក្តី ក៏ដីកាដំណោះស្រាយទាំងពីរ មានតម្លៃស្មើគ្នា ព្រោះមិនមានដីកាដំណោះស្រាយណាមួយ ត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុបរបស់អង្គបុរេជំនុំជម្រះឡើយ ហើយគោល

---

[82] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១២។

[83] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/០២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) អនុស្សរណៈអន្តរការិយាល័យ៖ ការបញ្ជាក់បំភ្លឺលើសេចក្តីសម្រេច ក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ឯកសារ D359/34។

[84] សំណើរបស់ ស.ព.អ. កំណត់សម្គាល់ ១៨។

[85] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៥៣, ៦៧។

ការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* តម្រូវថា ដីកាសម្រេចលើកលែងចោទប្រកាន់ មានអនុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[86]។

២៧. ស.ព.អ. បានអះអាងដោយភាន់ច្រឡំដោយមិនមានសំអាងថា សហចៅក្រមស៊ើបអង្កេត មានការទទួលខុសត្រូវចម្បង ក្នុងការផ្ទេរសំណុំរឿង[87]។ ក្របខណ្ឌ អ.វ.ត.ក. មិនបានចែងថា សហចៅក្រមស៊ើបអង្កេត ត្រូវទទួលខុសត្រូវលើការបញ្ជូនសំណុំរឿងឡើយ។ "អង្គជំនុំជម្រះសាលាដំបូង ទទួលសំណុំរឿងត្រឹមត្រូវតាមច្បាប់ ក្នុងករណីដែលអង្គបុរេជំនុំជម្រះ បញ្ជូនសំណុំរឿងពាក់ព័ន្ធ ដោយផ្អែកតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក."[88]។

២៨. ស.ព.អ. បានអះអាងដោយភាន់ច្រឡំថា ដោយសារតែសហចៅក្រមស៊ើបអង្កេត បានទទួលដំណឹងអំពីសេចក្តីពិចារណាហើយ ដូច្នេះ ពួកគេ "អាច និង ត្រូវតែអនុវត្តវិធាន ៦៩(២)(ក) *ដូចគ្នាទៅនឹង*" ត្រូវបង្គាប់ឱ្យផ្នែកគ្រប់គ្រងតុលាការ បញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង[89]។ ប្រភពដែល ស.ព.អ. បានដកស្រង់ជាសំអាង គឺខុសពីការអះអាងរបស់គាត់។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ មានទស្សនៈថា សហចៅក្រមស៊ើបអង្កេត "*បំពេញតួនាទីរបស់ខ្លួនចប់សព្វគ្រប់ហើយ* ... លើកលែងតែតួនាទីផ្នែករដ្ឋបាល *ដែលមានចែងច្បាស់នៅក្នុង ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.*"[90]។ វិធាន ៦៩(២)(ក) ចែង*យ៉ាងច្បាស់*ថា "*នៅពេលដែលគ្មានបណ្តឹងឧទ្ធរណ៍*ប្រឆាំងនឹងដីកាដំណោះស្រាយ" និង ប្រសិនបើមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រម

---

[86] អង្គបុរេជំនុំជម្រះ មានកំហុសអង្គច្បាប់ ក្នុងការសម្រេចថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអាចអនុវត្តបាន ដោយសារតែគោលការណ៍នេះ "កើតចេញពីគោលការណ៍ សច្ចធារណ៍នៃនិរទោស"។ សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ៧៧។ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រូវអនុវត្តនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី រួមទាំងដំណាក់កាលបុរេជំនុំជម្រះ និង អនុវត្តទាំងទៅលើអង្គហេតុ និង ការបកស្រាយទៅលើបទប្បញ្ញត្តិអង្គច្បាប់។ ដោយពិចារណាទៅលើភាពបត់បែននៃពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" ដែល "ពិតជាតម្រូវឱ្យមានចន្លោះនៃការយល់ឃើញ" វិមតិសង្ស័យទាំងអស់ ចំពោះយុត្តាធិការរបស់ អ.វ.ត.ក. ទៅលើលោក មាស មុត ចាំបាច់ត្រូវដោះស្រាយជាប្រយោជន៍ឱ្យរូបគាត់។ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/4 ("បណ្តឹងឧទ្ធរណ៍របស់ មាស មុត") កថាខណ្ឌ ៤៩-៧២ *ជាពិសេស* កថាខណ្ឌ ៥១។

[87] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១៣។

[88] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៧១ (i) (ការគូសបញ្ជាក់បន្ថែម)។

[89] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១៣។

[90] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៣២។

ស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង[91]។ ដោយពិចារណាថា មានបណ្ដឹងឧទ្ធរណ៍ជាច្រើន ត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្ដី ០០៤/២ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានយល់ឃើញថា សហចៅក្រមស៊ើបអង្កេត "មានការភាន់ច្រឡំដោយចេញដីការបស់ខ្លួន បង្គាប់ឱ្យបោះត្រា និង ដាក់សំណុំរឿងបញ្ចូលទៅក្នុងបណ្ណសារ ដោយផ្អែកលើវិធាន ៦៩(២)(ខ) *ដូចគ្នា*"[92]។

២៩. ស.ព.អ. បានពឹងផ្អែកដោយភាន់ច្រលំ ទៅលើការអះអាងរបស់អង្គបុរេជំនុំជម្រះដែលថា ខ្លួន "បំពេញមុខងាររបស់សភាស៊ើបសួររបស់កម្ពុជា" នៅក្នុងការអះអាងថា "នីតិវិធីដែលបានគូសបញ្ជាក់នៅទីនេះ ស្របគ្នាទាំងស្រុងជាមួយនឹងនីតិវិធី ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ទាក់ទងនឹងបញ្ហានោះ"[93]។ អង្គបុរេជំនុំជម្រះរៀបចំខ្លួនឯង ដូចជាសភាស៊ើបសួរ[94]។ ទោះបីជាបានចំណាយដល់ទៅ ២៣ កថាខណ្ឌ នៅក្នុងសេចក្ដីពិចារណាក្នុងរឿងក្ដី ០០៤/២ ដើម្បីពន្យល់ពីសិទ្ធិអំណាចរបស់ខ្លួន នៅដំណាក់កាលស៊ើបអង្កេតក្ដី តែដោយមិនអាចពន្យល់បាន អង្គបុរេជំនុំជម្រះ ជ្រើសរើសយកការ *មិន* ប្រើប្រាស់សិទ្ធិអំណាចទាំងអស់នោះ *មិន* ធ្វើការស៊ើបអង្កេត និង *មិន* ចេញដីកាដំណោះស្រាយ ដែលបានកែប្រែថ្មី[95]។ ដោយគួរឱ្យកត់សម្គាល់ សូម្បីតែក្រោយពេលអង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់ជាថ្មីនូវសិទ្ធិអំណាចរបស់អង្គបុរេជំនុំជម្រះ អនុវត្តហួសពីការប្រកាសពីភាពខុសច្បាប់ និង ចេញដីកាដំណោះស្រាយដែលមានសុពលភាព ដោយខ្លួនឯងក្ដី តែអង្គបុរេជំនុំជម្រះជ្រើសរើសយកកលយុទ្ធបិទផ្លូវយ៉ាងប្រាកដ[96]។

៣០. ស.ព.អ. បានអះអាងដោយភាន់ច្រឡំថា តាមមាត្រា ២៨២ និង ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "នៅពេលដែលចៅក្រមស៊ើបអង្កេត ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ គាត់ត្រូវបញ្ជូនសំណុំ

[91] វិធាន ៦៩(២)(ក) នៃវិធានផ្ទៃក្នុង (ការគូសបញ្ជាក់បន្ថែម)។

[92] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កំណត់សម្គាល់ ២៣១។

[93] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១៤។

[94] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៤/១ កថាខណ្ឌ ២២។ សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៤/២ កថាខណ្ឌ ៣០។

[95] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៤/២ កថាខណ្ឌ ៣១-៥៤។ សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ៤៣-៤៩, ១២០-១៣០។

[96] *សូមមើល ខាងលើ* កថាខណ្ឌ ១-១៥។

រឿងនោះជាបន្ទាន់ទៅកាន់ប្រធានតុលាការ ដើម្បីកំណត់កាលវិភាគសម្រាប់ការជំនុំជម្រះ"[97]។ ផ្ទុយទៅវិញ មាត្រា ២៨២ ចែងថា *សភាស៊ើបសួរ* មិនមែនចៅក្រមស៊ើបអង្កេតទេ ទទួលខុសត្រូវលើការបញ្ជូនសំណុំរឿង បន្ទាប់ពីស៊ើបអង្កេតរឿងក្តីដោយខ្លួនឯង និង ចេញដីកាដំណោះស្រាយដែលកែប្រែរួចៈ

> កាលណាសភាស៊ើបសួរសម្រេចថា បន្តការស៊ើបសួរដោយខ្លួនឯងនោះ សភាស៊ើបសួរប្រគល់ភារកិច្ចទៅសមាជិកខ្លួនម្នាក់ ដែលប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ ...។ សភាស៊ើបសួរ បិទការស៊ើបសួរ តាមសាលដីកាដំណោះស្រាយ។ បទប្បញ្ញត្តិនៃមាត្រា ២៤៧ (ដីកាដំណោះស្រាយ) ដល់មាត្រា ២៥០ (ការបញ្ជូនដើម្បីបើកសវនាការជំនុំជម្រះ) ស្តីពីដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនៃក្រមនេះ *ត្រូវយកមកអនុវត្តលើសាលដីកាដំណោះស្រាយរបស់សភាស៊ើបសួរ*[98]។

ការជូនដំណឹង ក៏អង្គបុរេជំនុំជម្រះ មិនបានអនុវត្តនូវមាត្រា ២៨២ ដែរ ដោយជ្រើសរើសជាជំនួសវិញនូវការ *មិន* ស៊ើបសួរទៅលើសំណុំរឿងដោយខ្លួនឯង និង *មិន* ចេញដីកាដំណោះស្រាយដែល កែប្រែថ្មី[99]។

៣១. ស.ព.អ. បានអះអាងដោយភាន់ច្រឡំថា សំណុំរឿង ០០៣ ចាំបាច់ត្រូវបញ្ជូនតទៅអង្គជំនុំជម្រះសាលាដំបូងភ្លាមៗ ដើម្បីគោរពតាមវិធានផ្ទៃក្នុង និង បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "ដើម្បីធានាបាននូវការអនុវត្តតាម "គោលការណ៍រួមដែលថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក. ចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌតម្រូវនៃនីត្យានុកូលភាព ភាពត្រឹមត្រូវ យុត្តិធម៌ និង ប្រសិទ្ធិភាព តាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក. ដើម្បីសម្រេចបាន "យុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធិភាព"[100]។ វិធានផ្ទៃក្នុង ក៏ដូចជាបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានចែងថា សហចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង នៅពេលដែលមានបណ្តឹងឧទ្ធរណ៍ប្តឹងមកអង្គបុរេជំនុំជម្រះ ហើយអង្គបុរេជំនុំជម្រះ មិនបានចេញដីកាដំណោះស្រាយដែលកែប្រែរួច និង នៅតែនៅមានសំណុំរឿងក្តីក្នុងដៃ ដោយសារតែអង្គបុរេជំនុំជម្រះបានបញ្ឈប់ខ្លួនឯងដោយមិន

---

[97] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១៤។

[98] ការគូសបញ្ជាក់បន្ថែម។

[99] *សូមមើល ខាងលើ* កថាខណ្ឌ ១, ៨, ១៥។

[100] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១៥ (ការដកស្រង់ផ្ទៃក្នុង ត្រូវបានលុបចោល)។

"ផ្តល់នូវការសម្រេចស្ថាពរជាក់ស្តែង"[101]។

៣២. ស.ព.អ. បានអះអាងដោយភាន់ច្រឡំថា គោលការណ៍នៃការបន្តកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ ឬ ការចោទប្រកាន់នៅក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក. ចែងថា សហចៅក្រមស៊ើបអង្កេតម្នាក់អាចបំពេញកិច្ចតែម្នាក់ឯង ដើម្បីបញ្ជូនសំណុំរឿងបន្តទៅអង្គជំនុំជម្រះសាលាដំបូង ជាពិសេស នៅពេលដែលសហការីរបស់គាត់ បានដកខ្លួនចេញពីការបន្តការស៊ើបអង្កេតនោះ[102]។ បើទោះបីជាមានគោលការណ៍នៃការបន្តនៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ក្តី ក៏រឿងក្តី ០០៣ មិនអាចបន្តទៅដំណាក់កាលជំនុំជម្រះ ដោយអវត្តមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលសុពលភាពនោះឡើយ[103]។ ម្យ៉ាងវិញទៀត បើទោះបីជាដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព នោះ ដីកាសម្រេចលើកលែងចោទប្រកាន់ក៏មានសុពលភាពដែរ ដែលតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវតែមានឧត្តមានុភាព[104]។

៣៣. ស.ព.អ. បានទទូចដោយភាន់ច្រឡំ ដល់សហចៅក្រមស៊ើបអង្កេត "កុំរាប់បញ្ចូលភវនីយភាពដែលមានលក្ខណៈទាយស្មានខ្លាំង និង មិនប្រាកដប្រជានេះ" ថា រឿងក្តីរបស់ អ.វ.ត.ក. ដែលគ្មានវិវឌ្ឍន៍ទៅដំណាក់កាលជំនុំជម្រះ នឹងត្រូវចោទប្រកាន់នៅក្នុងតុលាការកម្ពុជាធម្មតា[105]។ "គម្លាតនិទណ្ឌភាពជាខ្លាំង សម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ... *មិន* ត្រូវមានឥទ្ធិពលផ្នែកគោលនយោបាយ" មកលើការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតទេ[106]។

**អាស្រ័យហេតុនេះ** សហចៅក្រមស៊ើបអង្កេត គួរ**សម្រេចថា** សំណើរបស់ ស.ព.អ. មិនអាចទទួលយកបាន និង **បដិសេធ** សំណើរបស់ ស.ព.អ.។

សូមលោកចៅក្រមទទួលយកសេចក្តីគោរពអំពីយើងខ្ញុំ។

---

[101] សេចក្តីសម្រេចរបស់អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦១។

[102] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១៦។

[103] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦៨។

[104] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៤៩-៧២។

[105] សំណើរបស់ ស.ព.អ. កថាខណ្ឌ ១៧។

[106] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/០២/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០) ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ២៥ (ការគូសបញ្ជាក់បន្ថែម)។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១១** ខែ**ឧសភា** ឆ្នាំ **២០២១**

**សហមេធាវីការពារក្តីលោក មាស មុត**

___________________ _________________________

អាង ឧត្តម Michael G. KARNAVA